# សេរីភាពខាងការប្រជុំ

ដូចដែលយើងបានរៀនមកហើយថា សេរីភាពខាងការបញ្ចេញមតិ រួមចំណែកក្នុងការធ្វើឱ្យប្រសើរឡើងនូវការទាក់ទងគ្នារវាងប្រជាជន ធានានូវការចូលរួមរបស់ពួកគេនៅក្នុងសង្គម និងធ្វើឱ្យប្រសើរឡើងនូវការទទួលខុសត្រូវ និងតម្លាភាពនៃដំណើរការបង្កើតមតិ ។

នៅក្នុងសង្គមប្រជាធិបតេយ្យ និងពហុបក្ស ប្រជាជនអាចអនុវត្តនូវសេរីភាពក្នុងការបញ្ចេញមតិរបស់ពួកគេតាមរបៀបផ្សេងៗគ្នាជាច្រើន ដូចជាសរសេរអត្ថបទផ្ញើទៅកាសែត ពិភាក្សាជាមួយសមាជិកគ្រួសារ និងមិត្តភ័ក្ត្រ ដោយការគូរគំនូរត្លុក ឬការចុះផ្សាយជារូបភាព និងតាមវិធីជាច្រើនទៀត ។ គេអាចអនុវត្តសេរីភាពក្នុងការបញ្ចេញមតិនេះ ជាបុគ្គលតែម្នាក់ ។

ប៉ុន្តែ ប្រភេទនៃការបញ្ចេញមតិដែលមានអំណាច និងប្រសិទ្ធិភាពជាងនេះ គឺការមកជុំគ្នាជាមួយមនុស្សដទៃ ទៀត ដើម្បីផ្លាស់ប្តូរ ពិភាក្សា ផ្តល់ការប្រឹក្សា និងចុះផ្សាយនូវគំនិត និងពត៌មាន ។ នៅពេលដែលប្រជាជនប្រមូលផ្តុំគ្នាដើម្បីបញ្ចេញមតិ ពួកគេអនុវត្តនូវសេរីភាពខាងការប្រជុំរបស់គេ ។ វាគឺជាសេរីភាពដែលកើតពីធម្មជាតិ គឺវាកើតមកជាមួយ ។ វាមិនមែនជាអភ័យឯកសិទ្ធិដែលអាចត្រូវផ្តល់ ឬមិនត្រូវផ្តល់ឱ្យដោយរដ្ឋាភិបាលក្នុងនាមជាឆន្ទានុសិទ្ធិឡើយ ពោលគឺវាជាសិទ្ធិដែលមិនអាចដកហូត ឬ ផ្ទេរបាន ។

សិទ្ធិមនុស្សជាមូលដ្ឋាននៃសេរីភាពខាងការប្រជុំ ត្រូវបានចែងនៅក្នុងៈ

> មាត្រា ៤១ ប្រយោគទី១ CC:
>
> ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ...

ព្រមទាំងនៅក្នុងៈ

> មាត្រា២១ ប្រយោគទី១ ICCPR:
>
> សិទ្ធិក្នុងការប្រជុំដោយស្ងប់ស្ងាត់ នឹងត្រូវបានទទួលស្គាល់...

ទំរង់រូបភាពជាក់លាក់មួយនៃសេរីភាពខាងការប្រជុំគ្នា គឺសិទ្ធិក្នុងការធ្វើកូដកម្ម (មាត្រា៣៧ នៃរដ្ឋធម្មនុញ្ញកម្ពុជា) ។

## ក. តួនាទីនៃសេរីភាពក្នុងការប្រជុំ

សេរីភាពខាងការប្រជុំ គឺជារូបភាពជាក់លាក់មួយនៃការប្រាស្រ័យទាក់ទងជាមួយមនុស្សដទៃ ។ សិទ្ធិមនុស្សមួយនេះ ដើរតួនាទីជាមេក្រូ ឬឧបករណ៍បំពងសំលេង (អំភ្លី)របស់សេរីភាពក្នុងការបញ្ចេញមតិ ដើម្បីឱ្យមនុស្សជាច្រើននាក់ទៀតបានដឹងអំពីទស្សនៈរបស់ក្រុមមួយ ។ ការបង្កើតឡើង និងការបញ្ចេញមតិជាសាធារណៈរួមគ្នា នៅក្នុងប្រទេសកម្ពុជា មានសារៈសំខាន់ជាងអ្វីៗទាំងអស់ អាស្រ័យដោយមានប្រជាជនចំនួនស្ទើរតែ ៤០% ដែលមិនចេះអក្សរសម្រាប់ពួកគេ វាគឺជាមធ្យោបាយតែមួយគត់ដើម្បីផ្លាស់ប្តូរ និងបញ្ចេញទស្សនៈរបស់គេទៅកាន់រដ្ឋអំណាច ។

គោលបំណងនៃសេរីភាពខាងការប្រជុំ គឺដើម្បីធ្វើឱ្យប្រជាជនលែងនៅឯកោ ហើយផ្តល់ដល់ពួកគេនូវអារម្មណ៍នៃការរស់នៅជាសហគមន៍ និងផ្តល់កម្លាំងដល់ពួកគេ ។

## ខ. ធាតុនៃសេរីភាពក្នុងការជួបប្រជុំ

តើអ្វីទៅជាការប្រជុំ?

ការប្រមូលផ្តុំគ្នា (ឬការធ្វើបាតុកម្ម)គឺ:

- ការប្រជុំមួយដោយ**ស្ងប់ស្ងាត់**នៃ
- **មនុស្សពីរ ឬច្រើននាក់**
- ដែល**មិនមានអាវុធ**
- នៅទីកន្លែង**ឯកជន** ឬ**សាធារណៈ, ខាងក្នុង** ឬ**ខាងក្រៅផ្ទះ**
- **ដោយមានបំណងរួមគ្នា** ដើម្បីបញ្ចេញមតិ គំនិត ឬពត៌មានទៅកាន់អ្នកដទៃ ។

**១.** ការប្រជុំ**ដោយស្ងប់ស្ងាត់** មានន័យថាជាការធ្វើបាតុកម្មអហិង្សា ដែលបាតុករមិនមានអាវុធ ឬឧបករណ៍ដែលគំរាមកំហែងដល់ជីវិត ហើយវាមិនបង្កការខូចខាតចំពោះទ្រព្យសម្បត្តិឯកជន ឬសាធារណៈ ឬក៏បង្កឱ្យមានការឈឺចាប់លើរាងកាយ ឬការស្លាប់ទៅលើមនុស្សដទៃ (មាត្រា៧ កថាខ័ណ្ឌ១ និងមាត្រា៨ នៃច្បាប់ស្តីពីបាតុកម្ម) ។

កុបកម្មប្រឆាំងនឹងជនជាតិថៃនៅថ្ងៃទី២៩ មករា ២០០៣ ជាឧទាហរណ៍ដែលដាច់ខាតមិនមែនជាបាតុកម្មដោយសន្តិវិធីទេ គឺជាបាតុកម្មដោយហិង្សា ។

ចូរប្រុងប្រយ័ត្ន: ទោះបីជាមនុស្សម្នាក់អាចចាត់ទុកបុព្វហេតុនៃការធ្វើបាតុកម្មថាដោយសន្តិវិធីក្តី វាអាចចាត់ទុកថាប្រកបដោយហិង្សា នៅពេលដែលវាទំនងណាស់ថានឹងក្លាយទៅជាហិង្សា ។ ដើម្បីបញ្ជាក់ថាបាតុកម្មមួយអាចនឹងក្លាយជាហិង្សានោះ អាជ្ញាធរត្រូវតែបង្ហាញសញ្ញាយ៉ាងជាក់លាក់ និងច្បាស់លាស់ ដែលផ្អែកលើការពិត គឺមិនមែនលើការសន្និដ្ឋានជាទ្រឹស្តីនោះឡើយ ។
វាមិនគ្រប់គ្រាន់ទេ ដែលគេគ្រាន់តែ "គិតថា" (សូមមើលមាត្រា៣ ប្រយោគ២, ច្បាប់ស្តីពីការធ្វើបាតុកម្ម) បាតុកម្មមួយនឹងក្លាយជាហិង្សានោះ ។

ឧទាហរណ៍នៃការចង្អុលបង្ហាញយ៉ាងជាក់លាក់ និងច្បាស់លាស់:
១. បទពិសោធន៍កាលពីអតីតកាល បង្ហាញថាការធ្វើបាតុកម្មរបស់ក្រុម មនុស្សជាក់លាក់មួយ តែងតែរីកដុះដាលទៅជាបាតុកម្មហិង្សា ។ បទពិសោធន៍ទាំងនេះ បង្ហាញថាបាតុកម្មនេះក៏នឹងក្លាយជាហិង្សាផងដែរ ។

២. ខិតប័ណ្ណដែលគេចែកក្នុងពេលធ្វើបាតុកម្ម ដោយអំពាវនាវឱ្យប្រើអំពើហិង្សាប្រឆាំងនឹងមនុស្ស ឬទ្រព្យសម្បត្តិ ជាសញ្ញាបង្ហាញថា បាតុកម្មនេះនឹងក្លាយជាបាតុកម្មហិង្សា។

៣. បាតុកម្មត្រូវបានធ្វើឡើងក្នុងគោលបំណងតែមួយគត់ ដើម្បីរារាំងឬ រំខានដល់បាតុកម្មមួយទៀត ។ គោលបំណងនេះជាសញ្ញាបង្ហាញថា ការប្រមូលផ្តុំគ្នានេះ គឺមិនមែនធ្វើឡើង ដើម្បីបញ្ចេញមតិណាមួយរួមគ្នា និងដោយស្ងប់ស្ងាត់ឡើយ ប៉ុន្តែគឺដើម្បីយាយីដល់បាតុករ ដទៃទៀត។ (ឧទាហរណ៍ "សមាគមក្មេងវត្ត" ដែលជាញឹកញាប់ទៅ បំបែកបាតុកម្មដទៃ, សូមមើលឃែមបូឌាដេលី, ចេញថ្ងៃទី៧ កុម្ភៈ ២០០៣)

## ២. តើអ្វីទៅដែលហៅថាគោលបំណងរួម?

ប្រជាជនប្រមូលផ្តុំគ្នាដោយមានគោលបំណងរួមមួយ ប្រសិនបើមានគោលដៅរួមមួយ ដើម្បីបញ្ចេញ ទស្សនៈ ឬមតិជាក់លាក់មួយ ។

ក) ឧទាហរណ៍:

នៅពេលដែលស្ត្រីចង់ប្រមូលផ្តុំគ្នានៅខាងមុខរដ្ឋសភា ដើម្បីសុំឱ្យគេអនុម័ត "ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ" គឺពួកគេធ្វើដូច្នេះ ដោយមានគោលដៅរួមដើម្បីទាក់ទាញនូវការយកចិត្តទុកដាក់ពីសាធារណៈចំពោះសំណើរបស់គេ ។

ខ) ឧទាហរណ៍:

ប្រជាជននាំគ្នាចោមរោម បន្ទាប់ពីមានគ្រោះថ្នាក់ចរាចរមួយ ដើម្បីមើលនូវអ្វីដែលកើតឡើង ។
តើនេះជាការប្រមូលផ្តុំគ្នាដែរឬទេ?
អត់ទេ ពីព្រោះប្រជាជនមិនមែនជួបជុំគ្នាដោយមានគោលបំណង ឬដោយមានចេតនាធ្វើអ្វីមួយជាមួយគ្នានោះទេ ។ ពួកគេ គ្រាន់តែនៅកន្លែងដូចគ្នា ក្នុងពេលតែមួយ ធម្មតាប៉ុណ្ណោះ ។

# គ. គ្រោះថ្នាក់នៃសេរីភាពខាងការប្រជុំ

ត្រូវចងចាំជានិច្ចថា រាល់ការដាក់កំហិតដែលបានពោលខាងលើទាំងអស់ មិនអាចត្រូវបានប្រើប្រាស់ជាតឹកតាងមួយ ដើម្បីហាមឃាត់នូវការប្រមូលផ្តុំគ្នាដោយសេរីដូច្នេះឡើយ ។ អាជ្ញាធរត្រូវតែចាត់វិធានការដែលមានប្រសិទ្ធិភាពដើម្បីធានានូវការប្រើសិទ្ធិក្នុងការប្រមូលផ្តុំគ្នា ។ ការដែលគេមិនបានធ្វើដូច្នេះ គឺវាប្រឆាំងនឹងច្បាប់រដ្ឋធម្មនុញ្ញ ក៏ដូចជាច្បាប់អន្តរជាតិ[៤៦] ។

បើគេពិនិត្យមើលការដាក់កំហិតមិនមានកំណត់ ទៅលើសេរីភាពខាងការប្រជុំខាងលើ ភ្លាមនោះគេនឹងដឹងអំពីគ្រោះថ្នាក់ចំពោះសិទ្ធិមនុស្ស ។

អាស្រ័យដោយការធ្វើបាតុកម្ម អាចមានអំណាចខ្លាំង ពេលខ្លះរដ្ឋអំណាចមានអារម្មណ៍ថាខ្លួនត្រូវបានគេគំរាមកំហែង ហើយព្យាយាមប្រើមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីបង្ក្រាបបាតុកម្មនោះ:

[៤៦] www.bayefsky.com/themes/assembly_concluding-observations.php

## ១. គ្រោះថ្នាក់សម្រាប់សេរីភាពខាងការប្រជុំ **មុននឹង**បាតុកម្មកើតឡើងៈ

១.១. រដ្ឋអំណាចទំនងជាកំណត់នូវការដាក់កំហិតប្រាំយ៉ាង ("សិទ្ធិរបស់អ្នកដទៃ", "ទំនៀមទំលាប់ល្អរបស់សង្គម" "សណ្តាប់ធ្នាប់សាធារណៈ" "សន្តិសុខជាតិ" និង"សុខភាពសាធារណៈ") យ៉ាងទូលំទូលាយបំផុត ពីព្រោះគេចង់ទុកចន្លោះសម្រាប់ការដាក់កំហិតឱ្យបានទូលំទូលាយបំផុត ។ ជួនកាលគេបដិសេធមិនអនុញ្ញាត ឱ្យធ្វើបាតុកម្មមួយ ហើយដោយធ្វើដូច្នេះ គេបានកម្រិតព្រំដែនចំពោះសេរីភាពខាងការប្រជុំរហូតដល់កម្រិតសូន្យ ។

ឧទាហរណ៍ៈ

នៅថ្ងៃទី២៦ ឧសភា ២០០៣ ស្ត្រីចំនួន៣២ក្រុមចង់ធ្វើបាតុកម្មនៅខាងក្រៅរដ្ឋសភា ដើម្បីឱ្យមានការចេញពង្រាងច្បាប់ស្តីអំពីអំពើហិង្សាក្នុងគ្រួសារ ។ ចំពោះពួកគេ ក្នុងនាមជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ វាមានសារៈសំខាន់ណាស់ ដើម្បីនិយាយដោយផ្ទាល់ទៅកាន់សមាជិកសភា និងមន្ត្រីរដ្ឋាភិបាលអំពីអ្វីដែលគេចង់បាន និងត្រូវការ ។ អភិបាលក្រុងភ្នំពេញ បានបដិសេធការធ្វើបាតុកម្មរបស់ស្ត្រីទាំងនោះ ហើយនិយាយថាបាតុកម្មរបស់គេនឹង "ប៉ះពាល់សន្តិសុខ និងសណ្តាប់ធ្នាប់ សាធារណៈនៅភ្នំពេញ" ។

ដូចដែលយើងបានរៀននៅក្នុងជំពូកមុនរួចមកហើយអំពីសេរីភាពក្នុងការនិយាយស្តី "សន្តិសុខជាតិ" មិនមែនមានន័យថារាល់ចំណាប់អារម្មណ៍ផ្អែកសន្តិសុខទាំងអស់របស់រដ្ឋាភិបាលនោះឡើយ គឺវាសំដៅទៅលើការគំរាម-កំហែងដល់អាយុជីវិត និងសន្តិសុខរបស់ជាតិទាំងមូល ។

គ្រោះថ្នាក់ចំពោះ "សណ្តាប់ធ្នាប់សាធារណៈ" មានន័យថាគឺជាការគំរាមកំហែងពិតប្រាកដ និងជាក់លាក់ចំពោះសន្តិសុខរបស់អ្នកដទៃនៅក្នុងអនាគតដ៏ខ្លីខាងមុខ ។ ការដែលគេគ្រាន់តែសន្និដ្ឋានអំពីការគំរាមកំហែងបែបនេះ មិនគ្រប់គ្រាន់ឡើយ ។

តើស្ត្រីមួយចំនួនដែលបានក្លាយជាជនរងគ្រោះនៃអំពើហិង្សាខ្លួនគេផ្ទាល់ ទោះបីជាពួកគេប្រមូលផ្តុំគ្នាក្នុងចំនួនច្រើនក៏ដោយ អាចជាការគំរាមកំហែងចំពោះសន្តិសុខជាតិទាំងមូល ឬមនុស្សដទៃយ៉ាងដូចម្តេច? អភិបាលក្រុងភ្នំពេញ ផ្អែកការសម្រេចចិត្តរបស់ខ្លួនតែលើការសន្និដ្ឋាន គឺមិនមែនលើសញ្ញាច្បាស់លាស់ ការពិត ឬបទពិសោធពីអតីតកាលច្បាស់លាស់នោះទេ (វាជាការបង្ហាញយ៉ាងច្បាស់លាស់ កាលពីអតីតកាលស្ត្រីតែងតែកាន់កាំភ្លើង បង្កឱ្យស្ទះចរាចរ ជេរប្រមាថសមាជិសភា ឬបង្កអំពើហិង្សា នៅពេលដែលពួកគេធ្វើបាតុកម្ម ប៉ុន្តែជាក់ស្តែងពួកគេមិនដែលធ្វើបែបនោះទេ!) ។

ផលវិបាកធ្ងន់ធ្ងរ និងគួរឱ្យព្រួយបារម្ភបំផុតនៃការបដិសេធដែលផ្ទុយរដ្ឋធម្មនុញ្ញ និងខុសច្បាប់របស់គាត់ គឺថាសិទ្ធិសេរីភាពខាងការប្រជុំរបស់ស្ត្រីមិនអាចត្រូវបានដកហូតទាំងស្រុងនោះទេ ហើយការអនុវត្តសិទ្ធិនេះនៅអនាគតត្រូវរងគ្រោះថ្នាក់ ពីព្រោះពេលនេះស្ត្រីមានអារម្មណ៍រារែក និងបាក់ទឹកចិត្តដោយសារតែការបដិសេធនោះ ។

នៅក្នុងករណីនេះ អភិបាលក្រុងបាននិយាយសំអាងទៅលើមាត្រា៣ ប្រយោគ២ នៃច្បាប់ស្តីពីបាតុកម្ម ដែលមិនអនុលោមតាមមាត្រា៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងមាត្រា២១ ICCPR ឡើយ[៤៧] ។ មាត្រានេះចែងថាៈ

> "... ប្រសិនបើអាជ្ញាធរដែលពាក់ព័ន្ធ **គិតថា**ការធ្វើបាតុកម្មដែលមានលក្ខណៈមួយដែលនាំទៅរកការបង្កនូវភាពចលាចលនោះ គេ**អាចហាមឃាត់**ការធ្វើបាតុកម្ម បាន... ។"

៤៧ www.bayefsky.com/themes/assembly_concluding-observations.php

លទ្ធភាពនៃការបដិសេធនេះ គឺជាការដាក់កំហិត "តាមព្រឹត្តន័យ" ទៅលើសិទ្ធិក្នុងការប្រជុំគ្នាដែលមានន័យ ថា វាលុបបំបាត់នូវសេរីភាពទាំងមូល សូម្បីតែមុនពេលដែលគេអាចប្រើប្រាស់សេរីភាពនោះ ។

ដោយហេតុផលដូចគ្នានេះ មាត្រា៤ ជំរើសទី២ នៃច្បាប់ស្តីពីបាតុកម្ម វាមិនអនុលោមទៅតាម មាត្រា២១ ICCPR ឡើយ ។ មាត្រា៤ ជំរើសទី២ នៃច្បាប់ស្តីពីបាតុកម្មចែងថា:

> "ប្រសិនបើមានបាតុកម្មណាមួយកើតឡើង ..... **ដោយគ្មានការអនុញ្ញាត**ពីអាជ្ញាធរមូលដ្ឋាននោះ អាជ្ញាធរមូលដ្ឋានអាចចាត់វិធានការដើម្បី**ហាមឃាត់**បាតុករនៅទីឯកន្លែង ។"

មាត្រា២ កថាខ័ណ្ឌ៣ និងមាត្រា៤ ជំរើសទី១ នៃច្បាប់ស្តីអំពីបាតុកម្ម តម្រូវឱ្យជូនដំណឹងជាមុនដល់អាជ្ញាធរមូលដ្ឋានអំពីបាតុកម្ម ។ បញ្ញត្តិទាំងនេះ ស្របតាមមាត្រា២១ ICCPR ពីព្រោះ វាមិនបានកម្រិតព្រំដែននៃសេរីភាពខាងការប្រជុំដូច្នោះឡើយ[៤៨] ។ ប៉ុន្តែ វាគ្រាន់តែចាំបាច់ដើម្បីអាចឱ្យប៉ូលីសធានាថាបាតុកម្មនេះ មិនមានការរំខានដោយបាតុកម្មប្រឆាំងមួយទៀត ឬដោយចរាចរមមារញឹកនោះឡើយ ។

ប្រុងប្រយ័ត្ន: នៅពេលដែលប្រជាជនប្រមូលផ្តុំគ្នាដោយឯកឯងនោះ ការផ្តល់ពតិមានជាមុន (ជូនដំណឹង) អាចមិនចាំបាច់ឡើយ ពីព្រោះ វាមិនត្រូវបានចាត់ទុកថាជាការប្រមូលផ្តុំគ្នាដោយឯកឯងនោះទេ ប្រសិនណាវាត្រូវបានប្រកាសនោះ ។ ប្រជាជន មកជួបជុំគ្នាដោយឯកឯងដោយពុំមានអ្នករៀបចំទេ ។

**១.២.** ទោះបីជាតម្រូវការនៃការសុំអនុញ្ញាតជាមុនដើម្បីធ្វើបាតុកម្មវាអនុលោមទៅតាមរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់អន្តរជាតិក៏ដោយ រយៈពេលដ៏ចង្អៀតនៃដំណើរការសុំអនុញ្ញាតច្បាប់នៅតែអាចរំលោភសេរីភាពខាងការប្រជុំ ។

> មាត្រា៣ កថាខ័ណ្ឌ១ ប្រយោគ២នៃច្បាប់ស្តីពីបាតុកម្ម:
> "អាជ្ញាធរ... អាចហាមឃាត់ការធ្វើបាតុកម្ម ដោយចេញជាសេចក្តីសម្រេចក្នុងរយៈពេល៤៨ម៉ោង ...
> មាត្រា៣ កថាខ័ណ្ឌ៣ នៃច្បាប់ស្តីអំពីការធ្វើបាតុកម្ម:
> ក្នុងករណីដែលមិនមានការឯកភាព អ្នករៀបចំបាតុកម្មអាចប្តឹងតវ៉ាទៅអាជ្ញាធរថ្នាក់លើទៀត ។ អាជ្ញាធរថ្នាក់លើគួរតែធ្វើសេចក្តីសម្រេច... ហើយគួរធ្វើទំនាក់ទំនងទៅអ្នកប្តឹងតវ៉ាក្នុងរយៈពេល២៤ម៉ោង ។"

គេត្រូវជូនដំណឹងដល់អាជ្ញាធរយ៉ាងហោចណាស់បីថ្ងៃមុននឹងថ្ងៃធ្វើបាតុកម្ម (មាត្រា២ កថាខ័ណ្ឌ៣ នៃច្បាប់ស្តីពីបាតុកម្ម) ។ អាជ្ញាធរផ្នែកហាមឃាត់ ចាំបាច់ត្រូវចេញសេចក្តីសម្រេចក្នុងរយៈពេល ៤៨ម៉ោង ហើយអាជ្ញាធរថ្នាក់លើបន្ទាប់ ត្រូវចេញសេចក្តីសម្រេចក្នុងរយៈពេល២៤ម៉ោង ។ រយៈពេលដ៏ចង្អៀតនេះ អាចរារាំងប្រជាជនមិនឱ្យប្រើប្រាស់សេរីភាពខាងការជួបប្រជុំរបស់គេ ។ ហេតុដូច្នេះ វាមិនស្របតាមរដ្ឋធម្មនុញ្ញ ពីព្រោះវាមិនបានទុកពេលវេលាគ្រប់គ្រាន់សម្រាប់ការត្រួតពិនិត្យផ្នែកតុលាការលើភាពស្របច្បាប់នៃការធ្វើសេចក្តីសម្រេចហាមឃាត់ ទោះបីជាដំណោះស្រាយដោយតុលាការត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាក្តី ។

> មាត្រា៣៩ CC:
> "ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួលជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃ អង្គការទាំងនោះ ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។"
> 
> មាត្រា១២៨ III CC:

[៤៨] កាតព្វកិ...
(សូម...

ឧទាហរណ៍:

នាថ្ងៃទី១ ខែឧសភា កសិករបានជូនដំណឹងដល់អាជ្ញាធរឃុំថា នាថ្ងៃទី៤ ខែឧសភាពួកគេនឹងធ្វើបាតុកម្មមួយនៅផ្សារ ។

អាជ្ញាធរឃុំបានហាមឃាត់បាតុកម្មនោះ ហើយបានផ្ញើសេចក្តីសម្រេចរបស់គេទៅកសិករវិញ ក្នុងរយៈពេល ៤៨ម៉ោង ក្រោយនៅថ្ងៃទី៣ ឧសភា ។

កសិករ បានដាក់បណ្តឹងតវ៉ាប្រឆាំងនឹងសេចក្តីសម្រេចនេះ ទៅអាជ្ញាធរខេត្តដែលបានបដិសេធបណ្តឹងតវ៉ានោះ ២៤ម៉ោង ក្រោយនៅថ្ងៃទី៤ ឧសភា ។

ដូច្នេះ នៅពេលនោះបាតុកម្មដែលគេស្រមៃចង់ធ្វើនោះគួរតែបានកើតឡើងរួចទៅហើយ (នៅថ្ងៃទី៤ ឧសភា) ប៉ុន្តែវាមិនអាចធ្វើបាន ពីព្រោះដំណើរការសុំការអនុញ្ញាតមិនទាន់សម្រេចបាននៅឡើយ ។ ករណីនៃការស្រមើស្រមៃនេះបង្ហាញថា ពេលវេលាកំណត់នៃមាត្រា៣ នៃច្បាប់ស្តីពីបាតុកម្ម អាចនាំទៅរកផលវិបាកមួយដែលថា គេមិនអាចធ្វើបាតុកម្មបានទាល់តែសោះ ។ សូម្បីតែបណ្តឹងរដ្ឋបាលទៅតុលាការក៏មិនអាចធ្វើឱ្យបានទាន់ពេលវេលាដែលត្រូវធ្វើបាតុកម្មឡើយ ។

១.៣. អាជ្ញាធរ រារាំង ប្រជាជនមិនឱ្យធ្វើដំណើរទៅដល់កន្លែងបាតុកម្ម:

ឧទាហរណ៍:

នៅថ្ងៃទី៩ កុម្ភៈ ២០០៣ គេបានដាក់ពង្រាយកងកម្លាំងប៉ូលីស និងរបាំងផ្លូវត្រូវបានដាក់នៅតាមផ្លូវធំៗមកកាន់ទីក្រុងភ្នំពេញ ដើម្បីរារាំងប្រជាជនមិនឱ្យចូលទីក្រុងធ្វើបាតុកម្ម ទាមទារឱ្យនាយករដ្ឋមន្ត្រីលាលែងពីតំណែង ។ អ្នកធ្វើដំណើរ និងអ្នកបើកបរត្រូវបានគេសួរថាតើគេកំពុងទៅកន្លែងណា និងតើការធ្វើដំណើរ ទៅទីនោះដើម្បីអ្វី ។ ប្រសិនបើគេឆ្លើយថា គេទៅចូលរួមបាតុកម្មនោះ គេនឹងត្រូវឃាត់មិនឱ្យធ្វើដំណើរទៅមុខទៀត ។ បាតុកម្មដែលគេស្រមៃថាចង់ធ្វើនោះ មិនត្រូវបានហាមឃាត់ដោយអាជ្ញាធរ ឬក៏មានសញ្ញាបង្ហាញថា វានឹងក្លាយទៅជាហិង្សានោះឡើយ ។

វិធានការដែលបានប្រើ បានកម្រិតព្រំដែននៃសេរីភាពខាងប្រជុំរបស់បាតុករ រហូតដល់កម្រិតមួយដែលពួកគេមិនអាចប្រើប្រាស់សិទ្ធិមនុស្សជាមូលដ្ឋានរបស់គេទាល់តែសោះ ។

សូម្បីតែបាតុកម្មប្រឆាំងដែលមានហិង្សារវាំខ្លាំងក្លា និងការប៉ះទង្គិចគ្នាដោយហិង្សាជាមួយបាតុករដទៃ ក៏មិនអាចបញ្ជាក់ថាវិធានការខ្លាំងបែបនេះ វាសមហេតុផលនោះដែរ ។ ផ្ទុយទៅវិញ វាជាការពិតណាស់ដែលអាជ្ញាធរមានកាតព្វកិច្ចដើម្បីបង្កើតនូវលក្ខខណ្ឌមួយចំនួន (ក្នុងករណីនេះ គឺការពារបាតុកម្មមួយប្រឆាំងនឹងអំពើហិង្សារបស់មនុស្សដទៃ) ដែលធានាថា សិទ្ធិជាមូលដ្ឋាននៃសេរីភាពខាងការប្រជុំអាចត្រូវបានប្រើប្រាស់ដោយគ្មានការរំខាន ។

**២.** គ្រោះថ្នាក់សម្រាប់សេរីភាពខាងការជួបប្រជុំ **ក្នុងអំឡុងពេល**ដែលបាតុកម្មកើតឡើង:

**២.១.** ប៉ូលីសត្រូវបានបំពាក់ដោយឧបករណ៍ច្រើនពេក ។ ពួកគេធ្វើឱ្យបាតុករភិតភ័យ ដោយការសម្តែងនូវអំណាចអាជ្ញាសឹករបស់គេ (ដូចជាកាន់កាំភ្លើង ។ល។) ហើយធ្វើឱ្យបាតុករមិនហ៊ានប្រើប្រាស់សិទ្ធិមនុស្សរបស់គេក្នុងការប្រមូលផ្តុំគ្នាដោយសេរីនោះឡើយ[៤៩] ។

**២.២.** ការតាមឃ្លាំមើលពីប៉ូលីសហួសហេតុពេក (ដូចជា ប៉ូលីស ១០០នាក់ ឃ្លាំមើលបាតុករ ១០នាក់) ។

**២.៣.** ការប្រើប្រាស់កម្លាំងហួសហេតុដោយប៉ូលីស (ឧទាហរណ៍ ដោយប្រើប្រាស់ដំបងឆក់ គ្រាប់កាំភ្លើង កៅស៊ូ ។ល។) ដែលបណ្តាលឱ្យមានរបួសស្នាមធ្ងន់ធ្ងរ និងរហូតដល់ស្លាប់នោះ ជាការរំលោភបំពានលើរដ្ឋធម្មនុញ្ញកម្ពុជា ក៏ដូចជាច្បាប់អន្តរជាតិ ។

ឧទាហរណ៍:

ពួកអ្នកភូមិបានប្រមូលផ្តុំគ្នា ដោយពួកគេចង់ឱ្យនាយកដ្ឋានជលផលនៃក្រសួងកសិកម្ម ឮអំពីបញ្ហារបស់គេ ប៉ុន្តែពួកគេត្រូវបានប៉ូលីសបំបែក ពីព្រោះអ្នកភូមិបានចាំផ្លូវចូលក្រសួងអស់រយៈពេលជាងបីម៉ោង ។ គេបានចោទជាសំនួរថាតើការស្លាប់របស់អ្នកភូមិម្នាក់ដោយគាំងបេះដូងនៅអាយុ ២៩ឆ្នាំ គឺជាលទ្ធផលដែលប៉ូលីសប្រើប្រាស់ដំបងឆក់ដើម្បីបំបែកហ្វូងបាតុករមែនឬក៏អត់នោះ ។

សកម្មភាពរបស់អ្នកភូមិ (គឺការរាំងផ្លូវចូលក្រសួង) មិនបានបញ្ចូលទៅក្នុងសេរីភាពខាងការប្រជុំរបស់គេឡើយ ។ ប៉ុន្តែ ការប្រើប្រាស់កម្លាំងដើម្បីបំបែកហ្វូងបាតុករអហិង្សា និងដោយស្ងប់ស្ងាត់ត្រូវតែធ្វើឡើងដោយសមាមាត្រ ។ ផ្ទុយទៅវិញ ការប្រើកម្លាំងកំលាំងហួសហេតុនោះរំលោភបំពានសិទ្ធិមនុស្ស ។



ប៉ូលីសប្រឆាំងបាតុកម្ម ចំនួន២០០នាក់ដែលបំពាក់ដោយកាំភ្លើងអាកា៤៧ និង ដំបងឆក់បានវាយបំបែកបាតុកម្មស្ងៀមស្ងាត់មួយ នៅខាងមុខរដ្ឋសភា កាលពី ថ្ងៃទី២១ ឧសភា ២០០៣ ។

ដើម្បីទប់ស្កាត់អំពើហិង្សា និងឥរិយាបថខុសច្បាប់របស់ប៉ូលីសនោះ រដ្ឋមានកាតព្វកិច្ច:

- ត្រូវផ្តល់ដល់ភ្នាក់ងារប៉ូលីសនូវឧបករណ៍ដែលមិនអាចបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្សឡើយ
- បណ្តុះបណ្តាលសិទ្ធិមនុស្ស ដល់ភ្នាក់ងារប៉ូលីសទាំងនោះ

[៤៩] ប្រការនេះ វាមិនអនុលោមទៅតាមមាត្រា២១ ICCPR ឡើយ (សូមមើល www.bayefsky.com/themes/assembly_concluding-observations.php)

## ឃ.ការដាក់កំហិតទៅលើសេរីភាពខាងការប្រជុំ

យើងបានរៀនមកថា សិទ្ធិមនុស្សត្រូវតែមានតុល្យភាព ដើម្បីធានាថាសមាជិកម្នាក់នៅក្នុងសង្គម អាចមានជីវិតរស់នៅមួយដែលមានសេចក្តីថ្លៃថ្នូរដែលរាល់សិទ្ធិមនុស្សរបស់គេទាំងអស់ត្រូវបានការពារយ៉ាងល្អ ប្រសើរ ។

សេរីភាពខាងការប្រជុំដែលគ្មានព្រំដែននោះ មិនមានត្រូវបានធានាឡើយ ពីព្រោះថាការប្រមូលផ្តុំមនុស្សច្រើន អាចបង្កឱ្យមានស្ថានភាពគ្រោះថ្នាក់ និងបញ្ហាធ្ងន់ធ្ងរជាច្រើន (អំពើហិង្សា, ស្ទះចរាចរ, មានការបំផ្លិច បំផ្លាញ ។ល។) ។ សេរីភាពខាងការប្រជុំដែលគ្មានព្រំដែន នឹងមានន័យថាមនុស្សគ្រប់រូបសុទ្ធតែអាចធ្វើបាតុកម្ម គ្រប់ពេលវេលា គ្រប់ទីកន្លែង និងដោយប្រើគ្រប់មធ្យោបាយ ។

ការនេះអាចនាំទៅរកស្ថានភាពដូចខាងក្រោមៈ ទំនាក់ទំនងដែលពុំមានតុល្យភាព ចំពោះសេរីភាពរបស់អ្នកដទៃដូចដែលនឹងបង្ហាញនៅក្នុងក្រាហ្វិកខាងក្រោមៈ




សេរីភាពរបស់ "ក"

សេរីភាពរបស់ "ខ"

ឧទាហរណ៍ៈ ការធ្វើបាតុកម្មនៅគ្រប់ទីកន្លែង តាមដងផ្លូវ ដោយមានអាវុធ មានសម្លេងឡូឡាខ្លាំង វាយតប់មនុស្សដទៃ និងវាយកំទេចទ្រព្យសម្បត្តិរបស់គេ។



ឧទាហរណ៍ៈ ដើម្បីមានសន្តិសុខ និងមិនមានការគំរាមកំហែងដល់រាងកាយ (សិទ្ធិរស់រាន) ការបើកបរនៅលើផ្លូវដែលមានចរាចរសុវត្ថិភាព (សិទ្ធិធ្វើដំណើរ), ការលក់របស់របរក្នុងនាមជាម្ចាស់ហាង (សិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិ និងសិទ្ធិប្រើប្រាស់កម្មសិទ្ធិ), ការសម្រាកពេលបាយថ្ងៃត្រង់ដោយស្ងប់ស្ងាត់ (សិទ្ធិរក្សាសុខភាពល្អ) ។

ដើម្បីធ្វើឱ្យមានតុល្យភាពរវាងសិទ្ធិមនុស្សផ្សេងគ្នានេះ សេរីភាពខាងការប្រជុំរបស់មនុស្ស "ក" ត្រូវតែកម្រិតព្រំដែនដើម្បីការពារសេរីភាពរបស់មនុស្ស "ខ" ប៉ុន្តែគេអាចធ្វើបានដោយប្រើច្បាប់ (មិនមែនដោយចេញជាក្រិត្យ, អនុក្រិត្យ ឬអ្វីដែលហៅ "សេចក្តីជូនដំណឹង" នោះឡើយ) **ដែលបានអនុម័តដោយរដ្ឋសភា** ។




រដ្ឋធម្មនុញ្ញកម្ពុជា បានចែងនូវការដាក់កំហិតទៅលើសេរីភាពខាងការប្រជុំ នៅក្នុង:

> មាត្រា៤១ ប្រយោគ២ CC:
>
> "... ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។..."

ដូចគ្នាដែរ កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR):

> មាត្រា២១ ប្រយោគ២ ICCPR:
>
> "... មិនត្រូវមានការដាក់កំហិតណាមួយ ដែលត្រូវដាក់ទៅលើការប្រើសិទ្ធិនេះ ឡើយ (លើកលែងតែ) ការដាក់កំហិតដែលធ្វើឡើងស្របតាមច្បាប់ ហើយដែលចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាព ឬសីលធម៌សាធារណៈ ឬក៏ការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។"

ព្រោះហេតុដូច្នេះ **ការដាក់កំហិតទៅលើសេរីភាពខាងការប្រជុំ** អាចធ្វើឡើង**តែ**ដើម្បីការពារ:

- សិទ្ធិរបស់អ្នកដទៃ (ឧទាហរណ៍ សិទ្ធិរបស់មនុស្ស "ខ", ICCPR "សិទ្ធិនិងសេរីភាពរបស់អ្នកដទៃ")
- ទំនៀមទំលាប់ល្អរបស់សង្គម (ICCP: "សីលធម៌")
- ច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ (ICCPR "សុវត្ថិភាពសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ")
- សន្តិសុខជាតិ
- សុខមាលភាពសាធារណៈ

## ខ. ភាពសមាមាត្រដើម្បីធានានូវការប្រើប្រាស់សេរីភាពខាងការជួបប្រជុំឱ្យបានពេញលេញ:

គ្រោះថ្នាក់ដែលបានរៀបរាប់ខាងលើ បានបង្ហាញថាវិធានការដាក់កំហិតមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់គ្រប់ប្រភេទនោះឡើយ គឺគេអនុញ្ញាតឱ្យប្រើប្រាស់តែវិធានការសមាមាត្រដែលកម្រិតព្រំដែននៃសិទ្ធិតាមវិធីដែលស្រាលបំផុតបើអាចធ្វើបាន ។

**"គោលការណ៍នៃភាពសមាមាត្រ"** ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)៖

> មាត្រា២១ ប្រយោគ២ ICCPR :
>
> "... គ្មានការដាក់កំហិតណាមួយ អាចដាក់ទៅលើការប្រើប្រាស់សិទ្ធិនេះឡើយ លើកលែងតែការដាក់កំហិតដែលអនុលោមទៅតាមច្បាប់ និងដែលចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាព ឬក៏ការការពារសិទ្ធិនិងសេរីភាពរបស់អ្នកដទៃ។"

ប្រសិនបើយើងដាក់វិធានការផ្សេងៗគ្នាដើម្បីការពារសេរីភាពរបស់មនុស្សម្នាក់ ដោយដាក់កំហិតលើសេរីភាពរបស់មនុស្សម្នាក់ទៀត នោះមានន័យថា វិធានការស្រាលបំផុតក្នុងការដាក់កំហិតលើសេរីភាពនេះ អាចត្រូវបានជ្រើសរើស ។

ឧទាហរណ៍៖

ដោយម្ខាង និស្សិតចំនួន ៥០០០នាក់ ប្រើប្រាស់សិទ្ធិរបស់គេក្នុងការប្រមូលផ្តុំគ្នា ហើយធ្វើបាតុកម្មតាមវិថី មុនីវង្ស ដើម្បីទាមទារឱ្យកែប្រែប្រព័ន្ធការសិក្សាអប់រំឱ្យកាន់តែប្រសើរ ។ ម្យ៉ាងទៀត ម្ចាស់ហាងចង់ប្រើប្រាស់សិទ្ធិក្នុងការរក្សាទ្រព្យសម្បត្តិ ហើយអ្នកធ្វើចរាចរចង់ប្រើប្រាស់សិទ្ធិក្នុងការធ្វើដំណើរដោយសេរី និងដោយសុវត្ថិភាពតាមផ្លូវមុនីវង្ស ។

វាមានវិវាទរវាងសេរីភាពក្នុងការជួបប្រជុំ និងសិទ្ធិលើលើកម្មសិទ្ធិ ។ វិធានការដែលសមាមាត្រ សំរាប់ដោះស្រាយវិវាទមានដូចខាងក្រោមនេះ៖

វិធានការពីស្រាលទៅខ្លាំង៖

**១.** វិធានការនៃការដាក់កំហិតទៅលើសេរីភាពខាងការជួបប្រជុំ **មុននឹង** បាតុកម្មកើតឡើង៖

**១.១. ដាក់លក្ខខ័ណ្ឌចំពោះបាតុកម្ម៖**

បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងថាបាតុកម្មនឹងកើតឡើង (សូមមើលមាត្រា២ កថាខ័ណ្ឌ៣ នៃច្បាប់ស្តីពីបាតុកម្ម) អាជ្ញាធរត្រូវតែពិនិត្យមើលគ្រោះថ្នាក់ធំៗ ដែលអាចកើតឡើងសំរាប់មនុស្សដទៃ និងសម្រាប់បាតុកម្មផ្ទាល់ (ត្រូវចងចាំថា៖ អាជ្ញាធរត្រូវតែប្រឹងប្រែងឱ្យអស់លទ្ធភាពដើម្បីធានាថា បាតុកម្មអាចធ្វើបាន!)

ឧទាហរណ៍៖

និស្សិតចំនួន ១០.០០០នាក់ ជូនដំណឹងដល់អាជ្ញាធរអំពីការធ្វើបាតុកម្មរបស់ពួកគេនៅលើដងផ្លូវមុនីវង្ស ។ មនុស្សច្រើនសន្ធឹកសន្ធាប់បែបនេះនៅលើដងផ្លូវធំតែមួយ អាចនឹងបង្កឱ្យមានបញ្ហាដល់ចរាចរ ជាពិសេសនៅពេលម៉ោងប្រញាប់ ។
ដើម្បីដោះស្រាយវិវាទនេះតាមបែបសមាមាត្រ អាជ្ញាធរអាចសរសេរសំបុត្រផ្ញើទៅអ្នកដឹកនាំបាតុកម្ម និងកំណត់នូវលក្ខខណ្ឌដូចតទៅ: "បាតុកម្មអាចធ្វើទៅបាននៅកន្លែងណាដែលមានផ្លូវថ្នល់តិច និងមិននៅក្នុងពេលម៉ោងប្រញាប់ ពីម៉ោង៧ ដល់ ៨:៣០ព្រឹក ម៉ោង១១:៣០ព្រឹក ដល់ ១:៣០រសៀល និងម៉ោង៤:៣០រសៀល ដល់ ៦:៣០ល្ងាច ។"

**១.២. ហាមឃាត់មិនឱ្យធ្វើបាតុកម្មតែម្តង** (មាត្រា៣ ប្រយោគ២នៃច្បាប់ស្តីអំពីបាតុកម្ម):

លទ្ធភាពផ្លូវច្បាប់ក្នុងការហាមឃាត់ប្រជាជនមិនឱ្យធ្វើបាតុកម្ម ត្រូវតែដោះស្រាយដោយអាជ្ញាធរដោយមានការប្រុងប្រយ័ត្ន និងអត់ធ្មត់បំផុត ពីព្រោះបម្រាមទាំងស្រុងបែបនេះ កាត់បន្ថយសេរីភាពខាងការប្រជុំ រហូតដល់កម្រិតសូន្យ ។

ប្រសិនបើអាជ្ញាធរចង់ហាមឃាត់ការធ្វើបាតុកម្មមួយ បន្ទុកភស្តុតាងដែលដែលចែងនៅក្នុងរដ្ឋធម្មនុញ្ញជាបន្ទុករបស់អាជ្ញាធរ ។

រដ្ឋអំណាចត្រូវ:

- បង្ហាញនូវ សញ្ញាច្បាស់លាស់ និងជាក់លាក់ដែលផ្អែកលើការពិត ដែលបញ្ជាក់ថាបាតុកម្ម ទំនងណាស់ថា នឹងក្លាយជាហិង្សា និង
- ផ្តល់នូវកម្លាំងប៉ូលីសឱ្យគ្រប់គ្រាន់ ដើម្បីទប់ស្កាត់កុំឱ្យបាតុកម្មក្លាយជាការគំរាមកំហែងជាក់លាក់ និងពិតប្រាកដ ចំពោះសន្តិសុខរបស់មនុស្សដទៃ ។

**ចូរប្រុងប្រយ័ត្ន:**
**ចំពោះបាតុកម្មភាគច្រើនបំផុត មាត្រា ៣ ប្រយោគ ២ នៃច្បាប់ស្តីពីបាតុកម្ម មិនអាចយកមកប្រើប្រាស់បានឡើយ ហើយអាជ្ញាធរមិនត្រូវយកមាត្រានេះជាមូលដ្ឋានផ្លូវច្បាប់ ដើម្បីហាមឃាត់ការធ្វើបាតុកម្មឡើយ ពីព្រោះ បំរាមទាំងស្រុងវាបានបំបិទនូវសេរីភាពខាងការប្រជុំ ហើយបង្កើតជាការរំលោភដ៏ធ្ងន់ធ្ងរមួយទៅលើសិទ្ធិមនុស្សនេះ។**

## ២. វិធានការដាក់កំហិតលើសេរីភាពខាងការប្រជុំ **ក្នុងអំឡុងពេល** ដែលបាតុកម្មកើតឡើង:

**២.១. ការដាក់លក្ខខណ្ឌ** ក៏អាច និងនៅតែអាចធ្វើបានក្នុងអំឡុងពេលដែលបាតុកម្មកើតឡើង ដើម្បីធានាឱ្យបាតុកម្មមានសុវត្ថិភាព ។

ឧទាហរណ៍:
ប្រជាជន ធ្វើបាតុកម្មនៅមុខទ្វារចូលរដ្ឋសភា ដោយធ្វើឱ្យសមាជិកសភាមិនអាចចូលទៅក្នុងបាន ។ វិធានការសមាមាត្ររបស់ប៉ូលីស អាចជាការប្រកាសតាមមេក្រូដូចខាងក្រោមនេះ:
"យើងសូមសំណូមពរឱ្យបាតុករទាំងអស់ ចេញពីបរិវេណទ្វារចេញចូលរបស់រដ្ឋសភា ។ ធ្វើដូច្នេះប៉ូលីស ដាក់លក្ខខណ្ឌថា បាតុកម្មអាចធ្វើឡើងតែនៅចិញ្ចើមផ្លូវម្ខាងទៀតតែប៉ុណ្ណោះ ។"

**២.២.** ប្រសិនបើបាតុករមានប្រដាប់ដោយអាវុធ ពួកគេអាចត្រូវគេ**ដកហូតយក** (មាត្រា ៥ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីបាតុកម្ម)

**២.៣.** ប្រសិនបើបាតុករ រឹងរូសមិនព្រមប្រគល់អាវុធទៅឱ្យប៉ូលិស ពួកគេអាចត្រូវ**ឃុំឃាំងបណ្តោះអាសន្ន** (មាត្រា៥ កថាខ័ណ្ឌទី២ នៃច្បាប់ស្តីពីបាតុកម្ម) ។

ក្រោយមកទៀត ត្រូវដោះលែងពួកគេមកវិញ ហើយអាវុធនោះត្រូវប្រគល់ឱ្យគេវិញ ប្រសិនបើអាវុធនោះមិនខុសច្បាប់ទេនោះ ។

**២.៤. ប្រសិនបើបាតុកម្មក្លាយជាហិង្សា** ពីព្រោះវិធានការដែលបានរៀបរាប់ខាងលើពីអក្សរ លេខ "២.១" ដល់លេខ "២.៣" មិនមានប្រសិទ្ធិភាពទេនោះ ប៉ូលិសអាចចាត់វិធានការ "**សមស្រប**" ដើម្បីបញ្ឈប់វា (មាត្រា ៦ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីបាតុកម្ម) ។ បាតុកម្មមួយត្រូវចាត់ទុកថាមានហិង្សានៅពេលដែលវាបង្កនូវការគំរាមកំហែងជាក់លាក់និងដោយផ្ទាល់ចំពោះសន្តិសុខរបស់មនុស្សដទៃ ។ ប្រសិនបើវាគឺជាករណីដូច្នេះ មែនវិធានការខាងក្រោមពីស្រាលទៅខ្លាំង អាចយកមកប្រើបាន:

ក. ប៉ូលីសអាច**ហាមឃាត់**បាតុកម្ម (មាត្រា៤ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីបាតុកម្ម) ។

ឧទាហរណ៍:

ប៉ូលិសអាចប្រកាសតាមមេក្រូថា: "សូមប្រកាសថា បាតុកម្មនេះត្រូវបានហាមឃាត់ ។ បាតុករ ត្រូវបានបញ្ជាឱ្យរំសាយ ។"

ខ. ប៉ូលីសអាចប្រកាស**បំរាមនោះជាលើកទីពីរ** ដើម្បីព្រមានបាតុករ (មាត្រា៤ កថាខ័ណ្ឌទី២ នៃច្បាប់ស្តីពីបាតុកម្ម ) ។

គ. ប្រសិនបាតុករ បន្តធ្វើបាតុកម្មដោយហិង្សា ពួកគេអាចត្រូវ**បំបែកដោយឧបករណ៍ដែលមិនមានគ្រោះថ្នាក់ដល់ជីវិត** ។

ត្រូវប្រើវិធានការស្រាលបំផុតមុន (ដោយព្រមាន និងបាញ់កាំភ្លើងឡើងលើ) ហើយនិងវិធានការខ្លាំងបំផុតត្រូវប្រើចុងក្រោយ (បាញ់ទៅលើបាតុករដែលមាន អាវុធ និងតដៃ) ។

# សេរីភាពក្នុងការប្រជុំ

## មុខងារ → ធាតុផ្សំ → គ្រោះថ្នាក់ → ការដាក់កំហិត → ភាពសមាមាត្រ

### មុខងារ

ចំណងទំនាក់ទំនង (ឧបករណ៍បន្លឺសំលេង សំរាប់មតិ)

បំបាត់ភាពឯកោ និង ផ្តល់អារម្មណ៍ជាការរួបរួមជាសហគមន៍ និងកំលាំង

ការចូលរួម

តម្លាភាព

ការទទួលខុសត្រូវ

### ធាតុផ្សំ

ការប្រមូលផ្តុំដោយសន្តិវិធីនៃ...

មនុស្សពីរ ឬច្រើន...

ដែលគ្មានអាវុធ...

នៅក្នុង ឬនៅក្រៅកន្លែងឯកជន ឬសាធារណៈ...

ជាមួយគោល-បំណងរួមមួយដើម្បីបង្ហាញពីទស្សនៈ គំនិត ឬពតិមានដល់ អ្នកដទៃ

### គ្រោះថ្នាក់

ការប្រើប្រាស់ឧបករណ៍ច្រើនហួសហេតុដោយកំលាំងប៉ូលីស

អាជ្ញាធរកំណត់ន័យទូលំទូលាយពេកដល់ការដាក់កំហិតដែលហាមប្រាមដល់បាតុកម្ម

អជ្ញាយុកាលដ៏ខ្លីសំរាប់បាតុករធ្វើបណ្តឹងអំពីការហាមឃាត់នោះ (មាត្រា ៣ ២ I និង III នៃច្បាប់ស្តីពី បាតុកម្ម

### ការដាក់កំហិត

**សិទ្ធិអ្នកដទៃ**
ដូចជា ជីវិត ទ្រព្យសម្បត្តិ កិត្តិយស

**ប្រពៃណីល្អនៃសង្គម**
ដូចជា ការគោរព ដល់ស្តេច មនុស្សចាស់ លោកសង្ឃ និងយាយជី

**ច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ**
របៀបប្រមូលផ្តុំមិនត្រូវបំពានដល់សណ្តាប់ធ្នាប់សាធារណៈទេ ដូចជា ចរាចរដែលរលូន និងមានសុវត្ថិភាព

**សន្តិសុខជាតិ**
ដូចជា ការវាយប្រហារដោយយោធាពីខាងក្រៅ

**សុខមាលភាពសាធារណៈ**
ដូចជា ជំងឺសារស៏ SARS

### ភាពសមាមាត្រ

ភារកិច្ចនៃបាតុករក្នុងការជូនដំណឹងជាមុនដល់អាជ្ញាធរ ៣ថ្ងៃមុនថ្ងៃធ្វើបាតុកម្ម

អាជ្ញាធរអាចកំណត់លក្ខខណ្ឌមួយ

ដកហូតអាវុធ និង (ក្នុងករណីចាំបាច់) ឃុំខ្លួនអ្នកប្រព្រឹត្តហិង្សា

ហាមប្រាម និង

បំបែកបាតុកម្មដែលហិង្សា

## ? សំនួរសិក្ខាទី ១៤

ក. សូមរៀបរាប់ពីបទបញ្ញត្តិច្បាប់ជាតិ និងអន្តរជាតិ (ចំនួនមាត្រា) ដែលការពារសេរីភាពក្នុងការរួមប្រជុំ។

ខ. តើអ្វីខ្លះជាការដាក់កំហិតលើសេរីភាពក្នុងការរួមប្រជុំ?

គ. នៅខែកុម្ភៈ ឆ្នាំ២០០៣ អង្គភាពនគរបាល អង្គភាពកងរាជអាវុធហត្ថ និងការបិទផ្លូវ បានបោះទីតាំងនៅតាមបណ្តាផ្លូវសំខាន់ៗជាច្រើនក្នុងក្រុងភ្នំពេញ ដើម្បីរារាំងមិនឱ្យក្រុមបាតុករចូលក្នុងក្រុង ។ ក្រុមបាតុករដែលមកពីខេត្តកណ្តាល កំពង់ចាម កំពង់ឆ្នាំង និងកំពង់ស្ពឺ បានជឿតាមការអំពាវរបស់ "ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា" ដែលជាសហគមន៍មួយមាន៥ក្រុម ឱ្យមកជួបជុំគ្នានៅក្រុងភ្នំពេញ ដើម្បីសំរេចធ្វើបាតុកម្មសុំឱ្យមានការដោះលែងនិស្សិតទាំងឡាយ និងអ្នកកាសែតដែលត្រូវចាប់ខ្លួនដោយសារកុបកម្មប្រឆាំងនឹងថៃ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣ ។ សមាជិករបស់ក្រុមប្រឹក្សានៃអ្នកឃ្លាំមើលមុននេះបន្តិចបានអំពាវនាវសុំឱ្យមានការលាលែងតំណែងរបស់សម្តចហ៊ុន សែន បានលុបចោលការជួបប្រជុំ ដោយសារវត្តមានរបស់ក្មេងវត្តជាក្រុមគាំទ្រ សម្តេចហ៊ុន សែន នៅក្បែររដ្ឋសភា (ដកស្រង់ចេញពីកាសែត The Cambodia Daily ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣)

តើវិធានការដែលប៉ូលីសចាត់ឡើង ស្របច្បាប់ ឬមិនស្របច្បាប់?

ឃ. នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០២ បាតុកម្មមួយដែលមានមនុស្សប្រហែល១៧៥នាក់ ដែលសង្ឃឹមថានឹងមានការពិភាក្សាអំពីផែនការកាប់ឈើជាមួយក្រុមហ៊ុនកាប់ឈើ និងនាយកដ្ឋានរុក្ខា ត្រូវបំបែករត់ខ្ចាត់ខ្ចាយនៅខាងក្រៅនាយកដ្ឋានរុក្ខា ដោយកំលាំងប៉ូលីស និងកងរាជអាវុធហត្ថ ដែលប្រើដំបងអគ្គិសនីវាយ ។ យោងតាមអ្នកតាមដាន ការកាប់ព្រៃឈើ "អង្គការសាក្សីពិភពលោក" មានមនុស្សចំនួន១២នាក់ត្រូវរងរបួស និងបុរសម្នាក់អាយុ២៩ឆ្នាំ បានស្លាប់បន្ទាប់ពីរយៈពេលជាច្រើនម៉ោងនៃការបំបែកការប្រមូលផ្តុំនោះ ប៉ុន្តែមូលហេតុដែលថាការស្លាប់ដោយសារតែជំងឺគាំងបេះដូងនោះនៅមិនទាន់ច្បាស់នៅឡើយទេ ។ មន្ត្រីប៉ូលីសបានបដិសេធចំពោះការដែលថាមន្ត្រីរបស់ពួកគេវាយក្រុមបាតុករ ប៉ុន្តែអះអាងថា ក្រុមបាតុករបានបិទរបងនាយកដ្ឋានរុក្ខា ហើយមន្ត្រីនគរបាលម្នាក់បានអំពាវនាវឱ្យក្រុមបាតុករចេញ (ដកស្រង់ចេញពីកាសែតចេញថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០២) ។

ប្រើបញ្ជីត្រួតពិនិត្យនៅទំព័រទី៥៦ និងឆ្លើយនូវសំនួរទាំងអស់មួយជំហានម្តងៗ!